# កុំទុកថ្ងៃស្អែក

(បទពាក្យ៩)

គ្រប់ជីវិត ស្ថិតលើលោក ជ្រកមេឃា
មានការងារ ជាភារៈ ជាក់តាមកាយ
ស្ទួយជីវី ពីខ្សត់ខ្សោយ អោយសប្បាយ
មិនត្រូវណាយ ឆ្ងាយគំនិត គិតវេលា។

ការអ្វីៗ ថ្មីឬចាស់ រហ័សធ្វើ
ព្រួយអើពើ លើនាទី លីជន្មា
ទាំងសូត្ររៀន ធ្យានគួចគិត ដិតទយា
ឆាប់ម្នីម្នា ជានិស្ស័យ លៃអោយជាប់។

ការតូចធំ ផ្ដិតគិតអាន ច្រានក្ដីខ្ជិល
លាងមន្ទិល ខិលខូចខុស ដុសអោយឆាប់
កុំបង្អង់ រងចាំក្រោយ អោយច្រេះចាប់
ជាទំលាប់ ភ័ព្វមិនល្អ តទៅមុខ។

ភារកិច្ច តិចឬច្រើន កើនឬស្មើ
ប្រញាប់ធ្វើ មើល៍ឱ្យសព្វ គ្រប់ទំនុក
កុំបណ្ដោយ អោយនៅសល់ យល់ស្មាញស្មុគ
ក្រែងផុតយុគ ទុកអសារ នាំអោយស្ដាយ។

ការថ្ងៃនេះ រិះរេរើ ធ្វើអោយហើយ
កុំទុកឡើយ កន្ទើយថ្វី លៃកុំណាយ
ការងារហើយ ស្បើយចិន្ដា ថ្លាចិត្តកាយ
ស្អែកមកអាយ ខ្វាយខ្វល់គិត កិច្ចការថ្មី...។

(២៦ មករា ២០០២)

ស្វាត សាលឿម